# សេចក្តីប្រកាសព័ត៌មានរួម

សម្រាប់ការផ្សាយបន្ទាន់

ថ្ងៃ ច័ន្ទ ទី ១៣ ខែ កក្កដា ឆ្នាំ ២០០៩

**"ផលិតនៅប្រទេសកម្ពុជា"**

**ពិធីសម្ពោធយុទ្ធនាការប្រកួតច្នៃម៉ូតសំលៀកបំពាក់ទូទាំងប្រទេសសម្រាប់កម្មករកម្មការនីកាត់ដេរ**

យុទ្ធនាការប្រកួតច្នៃម៉ូតសំលៀកបំពាក់ទូទាំងប្រទេសសម្រាប់កម្មករកម្មការនីកាត់ដេរលើកទីពីរ ក្រោមប្រធានបទ " **ខ្ញុំមានតំលៃ** " នឹងចាប់ផ្តើមសម្ពោធនៅ**ថ្ងៃ ពុធ ទី ១៥ ខែ កក្កដា ឆ្នាំ ២០០៩ វេលាម៉ោង ៩:០០ ព្រឹកនៅការិយាល័យអង្គការពលកម្មអន្តរជាតិ*គំរោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា*** ។យុទ្ធនាការនេះធ្វើឡើង ដើម្បីលើកកំពស់កម្មករកម្មការនីកាត់ដេរកម្ពុជា ឱ្យតំលៃទៅលើការងារដែលគេធ្វើ និងផ្តល់ឱកាសអោយពួកគេបង្ហាញពីទេពកោសល្យតាមរយៈការប្រកួតប្រជែងច្នៃម៉ូតសំលៀកបំពាក់ និងអាវយឺត។

យុទ្ធនាការ " **ខ្ញុំមានតំលៃ** " គឺជាយុទ្ធនាការរួមគ្នាមួយ ក្រោមកិច្ចសហប្រតិបត្តិការពីក្រសួងកិច្ចការនារី ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ *គំរោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា*នៃអង្គការពលកម្មអន្តរជាតិ សមាគមរោងចក្រកាត់ដេរនៅកម្ពុជា មជ្ឈមណ្ឌលឧស្សាហកម្មដើម្បីបង្កើនលទ្ធភាពផលិតសំលៀកបំពាក់ កម្មវិធីអភិវឌ្ឍន៍នៃអង្គការសហប្រជាជាតិ សហជីព និងទស្សនាវដ្តីតំលៃនារី ។

គោលបំណងនៃការរៀបចំយុទ្ធនាការនេះឡើង គឺដើម្បីលើកកំពស់តំលៃផ្ទាល់ខ្លួនរបស់កម្មករកម្មការនីកាត់ដេរ ដោយបង្កើនការយល់ដឹងដល់សង្គមអំពីការងារ សមត្ថភាព និងជំនាញរបស់ពួកគេ និងលើកទឹកចិត្តដល់ពួកគេឱ្យយល់ដឹងអំពីសក្តានុភាពរបស់ខ្លួន ដើម្បីបង្ហាញឱ្យឃើញថាមានការងារល្អសម្រាប់ពួកគេនៅក្នុងវិស័យកាត់ដេរ និងដើម្បីបង្កើនឱកាសដល់កម្មករកម្មការនីឱ្យមានការរីកចំរើនក្នុងអាជីព ខណៈពេលដែលគេបានរួមចំណែកធ្វើឱ្យឧស្សាហកម្មកាត់ដេរមានការរីកចំរើនក៏ដូចជាចូលរួមចំណែកក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមកម្ពុជា ។ លើសពីនេះទៅទៀត យុទ្ធនាការនេះអាចនឹងផ្តល់នូវទិដ្ឋភាពជាវិជ្ជមានជាសកលដល់ឧស្សាហកម្មកាត់ដេរកម្ពុជាតាមរយៈការចូលរួមពីសំណាក់អ្នកបញ្ជាទិញអន្តរជាតិ ។

ក្នុងពេលដែលការប្រកួតប្រជែងនេះ នឹងដើរតួនាទីជាព្រឹត្តិការណ៍ដែលមានជាលក្ខណៈកំសាន្ត យុទ្ធនាការនេះក៏នឹងបញ្ជាក់បង្ហាញពីចំនុចសំខាន់ផ្សេងៗទៀតដូចជា ព័ត៌មានអំពីឱកាសការងារនៅក្នុងឧស្សាហកម្មច្នៃម៉ូត ការយល់ដឹង

អំពីឧស្សាកម្ម និងចង្វាក់ផ្គត់ផ្គង់ អត្ថបទពិពិណនាអំពីកម្មករកម្មការនីក្មេងៗ និងអ្នកគ្រប់គ្រងដែលបាន"ផលិតវាឡើង" នៅក្នុងឧស្សាហកម្ម និងសារទាំងឡាយស្តីអំពីការវិវត្តន៍នៃឧស្សាហកម្ម និងក្តីរំពឹងទៅអនាគត ។

ឧស្សាហកម្មកាត់ដេរនៅតែបន្តដើរតួជាកំលាំងចលករឧស្សាហកម្មយ៉ាងសំខាន់របស់ប្រទេសកម្ពុជា។ ឧស្សាហកម្មនេះផ្តល់ការងារដោយផ្ទាល់ដល់ប្រជាជនជាង ៣០០ ០០០ នាក់ខាងផ្នែកផលិតកម្ម និងប្រមាណ ៣០ ០០០ នាក់ទៀតខាងផ្នែកការងារគ្រប់គ្រង ។ ឧស្សាហកម្មនេះក៏ផ្តល់ការងារឱ្យដល់វិស័យដទៃទៀត ដូចជាការដឹកជញ្ជូន ការផលិតក្រដាសឡាំង អ្នកលក់ចំណីអាហារជាដើម ។ល។ សូម្បីតែធ្វើការប៉ាន់ស្មានដោយប្រយ័ត្នប្រយែងបំផុតក៏ដោយ ឧស្សាហកម្មកាត់ដេរបានចូលរួមចំណែកដល់ជីវភាពប្រចាំថ្ងៃរបស់ប្រជាជនកម្ពុជាជាង ១,៧លាននាក់ តាមរយៈការផ្ញើប្រាក់ត្រឡប់ទៅកាន់ទីជនបទ និងតាមរយៈសកម្មភាពសេដ្ឋកិច្ចដោយផ្ទាល់។

កម្មករកម្មការនីកាត់ដេរទាំងអស់ មានសិទ្ធិផ្ញើម៉ូតសំលៀកបំពាក់ និងការច្នៃម៉ូតលើអាវយឺត របស់ពួកគេបានរហូតដល់ថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០៩ ។ ព្រឹត្តិការណ៍ចុងក្រោយនៃការប្រកួតនេះ នឹងធ្វើឡើងដោយមានការបង្ហាញម៉ូតដែលនឹងប្រព្រឹត្តិទៅនៅក្នុងខែ វិច្ឆិកា ឆ្នាំ ២០០៩។ នៅក្នុងពីធីប្រកួតចុងក្រោយនេះ ម៉ូតសំលៀកបំពាក់ដែលល្អបំផុតនឹងត្រូវបានដាក់បង្ហាញតាមរយៈការដើរបង្ហាញម៉ូត ។ អ្នកជាប់ជ័យលាភីនឹងត្រូវបានជ្រើសរើសដោយតំណាងមកពីស្ថាប័ននានាដែលពាក់ព័ន្ធនៅក្នុងវិស័យឧស្សាហកម្មកាត់ដេរកម្ពុជា។

នៅក្នុងពិធីដាក់សម្ពោធយុទ្ធនាការ នៅថ្ងៃ ទី ១៥ ខែ កក្កដា ឆ្នាំ ២០០៩ វេលាម៉ោង ៩:០០ ព្រឹក កម្មវិធី រួមមានសុន្ទរកថាពីសំណាក់ដៃគូសំខាន់ៗក្នុងឧស្សាហកម្ម ការបញ្ចាំងវីដេអូឯកសារខ្លីពី " **ខ្ញុំមានតំលៃ** " កាលពីឆ្នាំ២០០៧និងក្បួនម៉ូតូកង់បី និងស៊ីក្លូភ្ជាប់ជាមួយសារ "**ផលិតនៅប្រទេសកម្ពុជា**" ។

---

សំរាប់ព័ត៌មានបន្ថែម និងសំនួររបស់សារព័ត៌មានសូមទំនាក់ទំនង

លោក នី យូ មន្ត្រីទំនាក់ទំនងអង្គការពលកម្មអន្តរជាតិ-*គំរោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា*

អ៊ីម៉ែល: you@ilo.org

ទូរស័ព្ទ: ០១២ ៣៧៣ ៨៧៧